**ព្រះសហគមន៍កាតូលិក**
**ភូមិភាគកំពង់ចាម**

# សាររបស់លោកអភិបាល សិលា សួន ហាឡៃ
# រដូវអប់រំពិសេស ឆ្នាំ២០២៣

**បងប្អូនជាទីស្រឡាញ់**!

រដូវអប់រំពិសេសមកជិតដល់ហើយ! ព្រះសហគមន៍យើងកំពុងធ្វើដំណើររួមគ្នា ឆ្លងកាត់ព្យុះភ្លៀង ឆ្ពោះទៅរកសិរីរុងរឿង ដែលព្រះជាម្ចាស់បានរៀបចំសម្រាប់យើង។ យើងដឹងហើយថា ជម្ងឺកូវីដ១៩ បានបំផ្លាញជីវិតមនុស្សរាប់លាននាក់ ព្រមទាំងបន្សល់ទុកនូវការលំបាកជាច្រើនដល់ពិភពលោក ដូចជាបញ្ហាសេដ្ឋកិច្ចធ្លាក់ចុះ ទំនិញឡើងថ្លៃជាដើម។ សព្វថ្ងៃ ប្រទេសមួយចំនួនក៏កំពុងមានសង្គ្រាម បណ្តាលឲ្យប្រជារាស្ត្រជាច្រើនបាត់បង់ជីវិត មានការភ័យខ្លាច និងជួបការលំបាកគ្រប់បែបយ៉ាង។ ថ្មីៗនេះ ប្រទេសទួរគី និងប្រទេសស៊ីរី ក៏រងគ្រោះដោយសាររញ្ជួយដី ដែលបណ្តាលឲ្យមនុស្សជាច្រើនម៉ឺននាក់បាត់បង់ជីវិត។ ចំណែកឯខ្លួនយើងផ្ទាល់វិញ ក៏ជួបប្រទះនូវទុក្ខលំបាកជាច្រើនដែរ ទាំងផ្លូវកាយ និងផ្លូវចិត្ត។

ព្យុះភ្លៀងទាំងនេះ គឺជាការរំលឹកយើងអំពីភាពផុយស្រួយនៃជីវិតមនុស្ស ដែលនាំឲ្យយើងស្វែងរកព្រះជាម្ចាស់ជាទីពឹង ហើយក៏អាចទៅជាឧបសគ្គដែលនាំឲ្យយើងបាត់បង់ជំនឿ ព្រោះតែយើងឃើញថា ព្រះជាម្ចាស់មិនបានឆ្លើយតបនឹងការរំពឹងទុករបស់យើ។ ហេតុនេះ យើងគួរសួរថា **តើខ្ញុំត្រូវរស់នៅយ៉ាងដូចម្តេច ដើម្បីចូលក្នុងរដូវសែសិតថ្ងៃខាងមុខនេះឲ្យបានសមរម្យ**?

រដូវសែសិបថ្ងៃ គឺជាពេលវេលាមួយដែលព្រះសហគមន៍យកចិត្តទុកដាក់អប់រំបងប្អូនដែលត្រៀមខ្លួន ទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លង។ រដូវនេះ ក៏ជាពេលវេលាសម្រាប់ឲ្យគ្រីស្តបរិស័ទគ្រប់គ្នាអប់រំចិត្តគំនិតផ្ទាល់ខ្លួន ដើម្បីរស់នៅឲ្យបានកាន់តែល្អប្រសើរឡើង តាមជំនឿដែលព្រះជាម្ចាស់បានប្រទានឲ្យ។ ហេតុនេះ ខ្ញុំសូមរំលឹកបងប្អូនថា ព្រះសហគមន៍សកលបាននឹងកំពុងមានដំណើរការសន្និបាតសកល អំពីធ្វើដំណើររួមជាមួយគ្នា ហើយក៏កំពុងរៀបចំមហាសន្និបាតយុវជនពិភពលោក ដើម្បីរិះគិតរកមធ្យោបាយថ្មីសម្រាប់ការប្រកាសដំណឹងល្អក្នុងសម័យទំនើប។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានសរសេរលិខិតសម្រាប់រដូវសែសិបថ្ងៃនេះ ដោយភ្ជាប់អត្ថន័យនៃរដូវនេះ ទៅនឹងដំណើរនៃសន្និបាតព្រះសហគមន៍ ដែលឈានមកដល់កំរិតនៃទ្វីបនិមួយៗ។ សម្តេចប៉ាបបានរំលឹកយើងអំពីអត្ថបទព្រះគម្ពីរដំណឹងល្អ ដែលយើងនឹងស្តាប់នៅថ្ងៃអាទិត្យទី២ នៃរដូវអប់រំពិសេស គឺព្រះយេស៊ូបានប្រែទ្រង់ទ្រាយនៅលើភ្នំតាបរ័។

ដូចព្រះយេស៊ូបាននាំសាវ័កបីនាក់ឡើងលើភ្នំយ៉ាងណា ព្រះអង្គក៏អញ្ជើញយើងទាំងអស់គ្នា ឲ្យឡើងលើភ្នំជាមួយព្រះអង្គដែរ។ ការឡើងលើភ្នំ តែងតែមានការលំបាក ព្រោះផ្លូវចោទ ព្រមទាំងមានថ្មរដិបរដុបផង ក៏ប៉ុន្តែ នៅពេលដែលយើងទៅដល់កំពូលភ្នំ យើងប្រាកដជាមានអំណរសប្បាយលើសពីធម្មតា។ នៅលើភ្នំតាប័រ សាវ័កទាំងបីនាក់បានឃើញព្រះយេស៊ូប្រែទ្រង់ទ្រាយ និងឃើញលោកម៉ូសេ ព្រមទាំងព្យាការីអេលីសន្ទនាគ្នាជាមួយព្រះយេស៊ូ ពួកគេក៏មានអំណរសប្បាយយ៉ាងក្រៃលែង រហូតដល់មិនចង់ចុះពីលើភ្នំវិញទេ។

រដូវសែសិបថ្ងៃ ជាពេលវេលាមួយឲ្យយើងឡើងទៅលើភ្នំដើម្បីជួបព្រះយេស៊ូ ដែលប្រែទ្រង់ទ្រាយ គឺព្រះអង្គពោរពេញដោយសិរីរុងរឿង ភ្លឺចិញ្ចែងចិញ្ចាច។ សេចក្ដីនេះ ជួយរំលឹកយើងថា គោលដៅនៃជីវិតរបស់យើង គឺទៅទទួលសិរីរុងរឿងរួមជាមួយព្រះអង្គ។ ហេតុដូច្នេះ ចូរយើងយកពេលវេលាអធិដ្ឋាន ធ្វើសមាធិឲ្យបានច្រើន ដើម្បីឲ្យយើងបានជួបព្រះយេស៊ូ និងទទួលព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ ដោយសង្ឃឹមថា ថ្ងៃណាមួយយើងនឹងទទួលបាននូវសិរីរុងរឿងរួមជាមួយព្រះអង្គ។

នៅលើភ្នំតាប័រនោះ សាវ័កទាំងបី បានឮព្រះសូរសៀងបន្លឺពីលើមេឃមកថា៖ **“ចូរស្ដាប់ព្រះអង្គចុះ”** (មថ ១៧,៥)។ នេះជាកិច្ចការទីមួយ ដែលសម្ដេចប៉ាបបានរំឭកយើងឲ្យអនុវត្តដើម្បីចូលក្នុងរដូវសែសិបថ្ងៃ គឺយើងត្រូវព្យាយាមស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមរយៈការចូលរួមអភិបូជាក្ដី អានអត្ថបទព្រះគម្ពីរប្រចាំថ្ងៃក្ដី ឬដោយស្ដាប់ព្រះបន្ទូលតាមប្រព័ន្ធអ៊ីនធឺណិតក្ដី។ លើសពីនេះទៅទៀត យើងក៏អាចស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គតាមរយៈបងប្អូនរបស់យើងដែរ ហើយការស្ដាប់បងប្អូននេះ ណែនាំឲ្យយើងអាចធ្វើការជាមួយគ្នា ដើរជាមួយគ្នា ស្របតាមគោលការនៃសន្និបាតព្រះសហគមន៍សកល ដែលកំពុងតែមានដំណើរការសព្វថ្ងៃ។ តាមរយៈការស្ដាប់ព្រះបន្ទូលនេះ នាំឲ្យយើងស្គាល់ព្រះយេស៊ូកាន់តែច្បាស់ រស់នៅកាន់តែល្អប្រសើរក្នុងជំនឿរបស់យើង។

នៅពេលដែលសាវ័កទាំងនោះកំពុងភ័យខ្លាច ព្រះយេស៊ូមានបន្ទូលទៅគេថា៖ **“ចូរក្រោកឡើង កុំខ្លាចអី!”** (មថ ១៧,៧)។ នេះជាកិច្ចការទីពីរ ដែលសម្ដេចប៉ាបបានរំលឹកយើងឲ្យធ្វើនៅក្នុងរដូវសែសិបថ្ងៃនេះ គឺកុំឲ្យយើងភ័យខ្លាចចំពោះឧបសគ្គជាច្រើនដែលយើងជួប ហើយដែលអាចធ្វើឲ្យយើងទៅជាមនុស្សពិការ អសកម្ម មិនហ៊ានទៅជួបអ្នកដទៃ មិនហ៊ានប្រកាសដំណឹងល្អ និងប្រព្រឹត្តកិច្ចការសប្បុរសធម៌ក្នុងជីវិតប្រចាំថ្ងៃ។ ព្រះបន្ទូលព្រះយេស៊ូនេះ ជាការរំលឹក និងជាកម្លាំងរបស់យើងក្នុងរដូវអប់រំពិសេសឆ្នាំនេះ ដើម្បីឲ្យយើងអាចរស់នៅដោយជំនឿ ដោយសេចក្ដីស្រឡាញ់ និងដោយសេចក្ដីសង្ឃឹម។

សេចក្ដីណែនាំរបស់សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូសម្រាប់រដូវសែសិបថ្ងៃឆ្នាំនេះ មិនទៅណាឆ្ងាយពីរបៀបរស់នៅរបស់ព្រះសហគមន៍តាំងពីដើមដំបូងមកនោះទេ គឺក្នុងរដូវអប់រំពិសេស គ្រីស្ដបរិស័ទត្រូវយកចិត្តទុកដាក់ អធិដ្ឋាន តមអាហារ និងធ្វើទានដល់អ្នកក្រីក្រ។ ការអធិដ្ឋាននេះ នាំយើងឲ្យបានជិតស្និទ្ធជាមួយព្រះជាម្ចាស់ ដោយស្ដាប់ព្រះបន្ទូលព្រះអង្គ និងនិយាយទៅកាន់ព្រះអង្គនូវទុក្ខកង្វល់ អំណរសប្បាយ និងតម្រូវការរបស់យើង របស់បងប្អូនយើង។ ការតមអាហារ នាំឲ្យយើងរំងាប់នូវចិត្តលោភលន់ទាំងឡាយ លះបង់អំពើអារក្រក់ ចែករំលែកអាហារដល់បងប្អូនទីទាល់ក្រ។ ការធ្វើទាន ជាទង្វើមួយដែលនាំឲ្យយើងរស់នៅតាមសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ ដែលបានបូជាព្រះជន្មដើម្បីសង្គ្រោះមនុស្សលោក។

សូមព្រះជាម្ចាស់ប្រោសបងប្អូន ឲ្យបានជួបព្រះយេស៊ូជាប្រភពនៃសេចក្ដីប្រណីសន្ដោស និងសេចក្ដីស្រឡាញ់ដ៏លើសលប់។ សូមព្រះវិញ្ញាណណែនាំបងប្អូនឲ្យឈ្នះការល្បួងគ្រប់យ៉ាង ដើម្បីធ្វើដំណើរឆ្ពោះទៅកាន់ជីវិតដ៏ពេលលេញ ទទួលសិរីរុងរឿងរួមជាមួយព្រះគ្រីស្ដ។

**កំពង់ចាម ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣**

**លោកអភិបាល សិលា សួន ហាខ្សលី**

**អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគកំពង់ចាម**